# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

## កំណើនសេដ្ឋកិច្ចពិភពលោក

ផ្នែកនេះផ្ដោតលើសេដ្ឋកិច្ចធំបង១ក្នុងពិភពលោក និងសេដ្ឋកិច្ចភាគច្រើននៅអាស៊ីខាងកើត ។ ស្ថានភាពសេដ្ឋកិច្ចនៅបណ្ដាប្រទេសទាំងនោះមានលក្ខណៈទាក់ទងជាពិសេសទៅនឹងសេដ្ឋកិច្ចកម្ពុជា ។

នៅត្រីមាសទី២ឆ្នាំ២០០៧ ផសស ពិតនៅ US កើន ១,៩ % ខ្ពស់ជាងមួយឆ្នាំមុន ធៀបនឹងកំណើន ១,៥% នៅត្រីមាសមុន ។ រឿងនេះបណ្ដាលមកពីការធ្លាក់ចុះការនាំចូល កំណើនចំណាយរដ្ឋាភិបាលសម្ព័ន្ធ និងវិនិយោគលើទំនិញឯកជន ព្រមទាំង កំណើនការនាំចេញ សំណង់មិនមែនសំរាប់ស្នាក់នៅ និងគ្រឿងបរិក្ខា និងសូហ្វវែរ ។

ផសស ពិត នៅតំបន់អឺរ៉ូ កើន ២,៥% នៅត្រីមាសទី២ ធៀបនឹងអំឡុងពេលដូចគ្នាមួយឆ្នាំមុន និងកើន ០,៣% ធៀបនឹងត្រីមាសមុន ។ ផសស ពិត នៅជប៉ុន កើន ២,៣% ធៀបនឹងមួយឆ្នាំមុន និងកើន ០,១% ធៀបនឹងត្រីមាសមុន ។

សេដ្ឋកិច្ចចិន មានកំណើន ១១,៥% នៅត្រីមាសទី២ ខ្ពស់ជាងមួយឆ្នាំមុន ។ កំណើននេះនាំមុខដោយឧស្សាហកម្ម ដែលមានតំលៃបន្ថែមកើន ១៣,៦% ធៀបនឹងកំណើន ១០,៦% ក្នុងវិស័យសេវាកម្ម និង ៤,០% ក្នុងវិស័យកសិកម្ម ។ ផសស ពិត នៅកូរ៉េខាងត្បូង កើន ៤,៥% ធៀបនឹងមួយឆ្នាំមុន និងកើន ១,៨% ធៀបនឹងត្រីមាសមុន ។ សំរាប់ផ្នែកផលិតកម្មឧស្សាហកម្មផលិត និង សេវាកម្ម បានកើនឡើង រីឯការសាងសង់ធ្លាក់ចុះ ។ សំរាប់ផ្នែកចំណាយ ចំណាយប្រើប្រាស់ឯកជន មានសភាពប្រសើរឡើងជាបណ្ដើរ១ ស្របពេលដែលវិនិយោគលើគ្រឿងសំរួលការ និងការនាំចេញ បន្តលូតលាស់ខ្លាំង ។ ផសស ពិត នៅតៃវ៉ាន់ និង ហុងកុង មានកំណើន ៥,០៧% និង ៦,៩% ធៀបនឹងអំឡុងពេលដូចគ្នាមួយឆ្នាំមុន។

សេដ្ឋកិច្ចម៉ាឡេស៊ី មានកំណើន ៥,៧% ក្នុងរយៈមួយឆ្នាំដល់ត្រីមាសទី២ ឆ្នាំ២០០៧ ។ កំណើននៅត្រីមាសនេះ បានជំរុញខ្លាំងដោយ វិស័យសេវាកម្ម (៩,២%) រ៉ែ (៧,៧%) និង សំណង់ (៤,៨%) ។ សេដ្ឋកិច្ចនៅសិង្ហបុរី កើន ៨,២% ក្នុងរយៈ១២ខែប៉ុណ្ណោះ ។ ឧស្សាហកម្មផលិត និង សំណង់មានកំណើនខ្លាំងដល់ ១០,២% និង ១៧,៩% រីឯ សេវាកម្មមានកំណើនមធ្យម ៧,០% ។ ផសស ពិតនៅថៃ កើន ៤,៤% ខ្ពស់ជាងត្រីមាសទី២ ឆ្នាំ២០០៦ ។ វិស័យកសិកម្ម កើន ៩,៧% ខ្ពស់ជាងត្រីមាសមុន (៣,៣%) ដែលបណ្ដាលជាសំខាន់មកពីកំណើនផលដំណាំ និង ត្រី ។ វិស័យមិនមែនកសិកម្ម កើន ៤,០% ធៀបនឹងកំណើន ៤,៣% នៅត្រីមាសមុន។

## អតិផរណាពិភពលោក និង អត្រាប្ដូរប្រាក់នៅទីផ្សារអន្តរជាតិ

នៅត្រីមាសទី២ ឆ្នាំ២០០៧ ថ្លៃទំនិញប្រើប្រាស់នៅUS កើនតាមអត្រាប្រចាំឆ្នាំ ២,៧% ធៀបនឹង ២,៤% នៅត្រីមាសទី១ ។ រឿងនេះបណ្ដាលមកពីកំណើនថ្លៃម្ហូបអាហារ ថ្នាំពេទ្យ ផ្ទះស្នាក់នៅ និងថាមពល ។ នៅតំបន់អឺរ៉ូ មានអតិផរណា ១,៩% គឺគ្មានប្រែប្រួលពីត្រីមាសមុនទេ ។ កំណើនថ្លៃទំនិញក្នុងរយៈ១ឆ្នាំនេះ បណ្ដាលមកពីកំណើនអាករលើតំលៃបន្ថែមនៅអាឡឺម៉ង់ ។ នៅជប៉ុន ថ្លៃទំនិញប្រើប្រាស់ធ្លាក់ចុះ ០,១% ក្នុងរយៈមួយឆ្នាំដល់ត្រីមាសទី២ ។ នេះបណ្ដាលមកពីការធ្លាក់ថ្លៃកញ្ចប់ខ្សែទស្សនកិច្ចទៅក្រៅប្រទេស និងឧបករណ៍អេឡិចត្រូនិកសំរាប់ប្រើប្រាស់ក្នុងផ្ទះ ។ ប៉ុន្តែបំរែបំរួលនេះ វាតិចតួចសឹងស្មើសូន្យ បើសិនមិនរាប់បញ្ចូលនូវផលិតផលប្រេងកាត និងកត្តាពិសេស១ផ្សេងទៀត។

នៅទីផ្សារប្ដូរប្រាក់អន្តរជាតិ ដុល្លារUS ប្រែប្រួលមិនទៀងទាត់ ទល់នឹងរូបិយវត្ថុដទៃទៀត ។ ទល់នឹងប្រាក់យ៉េនជប៉ុន វាប្ដូរបាន ១២០,៨ យ៉េន/ដុល្លារUS ធៀបនឹង ១១៩,៤យ៉េន/ដុល្លារUS នៅត្រីមាសមុន ។ ការឡើងថ្លៃប្រាក់ដុល្លារទល់នឹងប្រាក់យ៉េនជប៉ុន បណ្ដាលមកពីគំលាតកាន់តែធំនៃអត្រាការប្រាក់ ។ ទល់នឹងប្រាក់អឺរ៉ូ ប្រាក់យ៉ុនចិន និងប្រាក់វ៉ុនកូរ៉េខាងត្បូង ដុល្លារUS ប្ដូរបាន ០,៧៤អឺរ៉ូ/ដុល្លារUS ៧,៦៨យ៉ុន/ដុល្លារUS និង ៩២៩វ៉ុន/ដុល្លារUS គឺធ្លាក់ថ្លៃ បើធៀបនឹងអត្រា ០,៧៦អឺរ៉ូ/ដុល្លារUS ៧,៧៦យ៉ុន/ដុល្លារUS និង ៩៣៩វ៉ុន/ដុល្លារUS នៅត្រីមាសទី១ ២០០៧ ។ ការធ្លាក់ថ្លៃដុល្លារUS គឺដោយសារអ្នកចូលរួមទីផ្សារ ធ្វើការវាយតំលៃថា ទៅអនាគតតំបន់អឺរ៉ូ ប្រទេសចិន និងប្រទេសកូរ៉េខាងត្បូង មានលក្ខណៈអំណោយផលជាង ។

## ថ្លៃទំនិញប្រើប្រាស់នៅទីផ្សារពិភពលោក

នៅត្រីមាសទី២ ប្រេងឆា សណ្ដែកសៀង ប្រេងឆៅ សាំង និង មាស៊ូតឡើងថ្លៃ រីឯ ពោត និង អង្ករធ្លាក់ថ្លៃ ។ ប្រេងឆាលក់បាន ៦៩១,៤៤ដុល្លារ/តោន ធៀបនឹង ៥៥២,០៦ដុល្លារ/តោន នៅត្រីមាសទី១ រីឯពោតលក់បាន ១៤៦,១០ដុល្លារ/តោន និង សណ្ដែកសៀង ២៥៩,៩៥ ដុល្លារ/តោន ។ អង្ករ Thai 100% B លេខ២ នៅទីផ្សារបាងកក លក់ថ្លៃ ២៨៣,៨៩ដុល្លារ/តោន ធៀបនឹង ២៩៤,១៧ដុល្លារ/តោន នៅត្រីមាសមុន ។ ប្រេងឆៅ ឡើងថ្លៃ

*តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០១-២០០៧ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)*

| | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2006 | | 2007 | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q3 | Q4 | Q1 | Q2 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 6.7 | 4.8 | 7 | 7.7 | 13.4 | 10.6 | - | - | - | - |
| ឥណ្ឌូនេស៊ី | 3.8 | 3.8 | 4.9 | 5.1 | 5.6 | 5.4 | 5.5 | 6.1 | - | - |
| ម៉ាឡេស៊ី | 0.5 | 5.6 | 5.4 | 7 | 5.2 | 5.9 | 5.8 | 5.7 | 5.3 | 5.7 |
| សិង្ហបុរី | -2.3 | 2.6 | 1.4 | 8.5 | 5.7 | 7.7 | 7.1 | 7.0 | 6.0 | 8.2 |
| ថៃ | 1.9 | 6.1 | 6.9 | 6 | 4.5 | 4.8 | 4.7 | 4.2 | 4.3 | 4.4 |
| វៀតណាម | 6.0 | 6.7 | 7 | 7.5 | 8.4 | 8.1 | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 7.5 | 8.1 | 9.9 | 9.5 | 9.6 | 10.5 | 10.4 | 10.7 | 11.1 | 11.5 |
| ហុងកុង | 0.5 | 5.0 | 3.2 | 8.3 | 6.5 | 6.6 | 6.8 | 7.0 | 5.6 | 6.9 |
| កូរ៉េខាងត្បូង | 3.0 | 6.1 | 3 | 4.7 | 4.7 | 5.0 | 4.8 | 5.0 | 4.0 | 4.5 |
| តៃវ៉ាន់ | -2.2 | 4.2 | 3.1 | 5.7 | 4.1 | 4.6 | 5.0 | 4.0 | 4.1 | 5.07 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 1.4 | 0.7 | 0.5 | 1.8 | 1.5 | 2.7 | 2.6 | 3.3 | 3.0 | 2.5 |
| ជប៉ុន | 0.4 | 0.4 | 2.6 | 3.4 | 2.5 | 2.1 | 2.7 | 2.3 | 2.2 | 2.3 |
| សហរដ្ឋអាមេរិក | 1.2 | 2.4 | 3.1 | 4.4 | 3.7 | 3.3 | 3.3 | 3.1 | 1.5 | 1.9 |

*Sources: Economist, countries' national statistics offices and central banks and ADB's Asia Regional Information Centre*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

២១% ធៀបនឹងត្រីមាសមុន ដល់ ៦៥,៤១ដុល្លារ/ធុង ។ សាំង និង ម៉ាស៊ូត ឡើងថ្លៃ គួរអោយចាប់អារម្មណ៍ ធៀបនឹងត្រីមាសមុន ដោយសាំង ឡើងថ្លៃ ៣៩% និង ម៉ាស៊ូត ១៨% ។ សាំង លក់បាន ៥៧,៩៣សេន/លីត្រ និង ម៉ាស៊ូត លក់បាន ៥៣,៩០សេន/លីត្រ។

*រៀបរៀងដោយ ហ៊ីង វុត្ថា និង ភីម រុនស៊ីណារិទ្ធិ*

*តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០១-២០០៧ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)*

| | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2006 | | 2007 | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q3 | Q4 | Q1 | Q2 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | -0.6 | 3.2 | 1.2 | 4.0 | 5.8 | 4.7 | 4.9 | 3.4 | 3.0 | 4.6 |
| ឥណ្ឌូនេស៊ី | 11.5 | 13.2 | 8.3 | 8.3 | 10.5 | 13.4 | 14.9 | 6.1 | 6.4 | - |
| ម៉ាឡេស៊ី | 1.4 | 1.8 | 1.1 | 1.6 | 3.1 | 3.7 | 3.6 | 3.1 | 2.6 | 1.4 |
| សិង្ហបុរី | 1.0 | -0.4 | 0.5 | 1.7 | 0.5 | 1.0 | 0.7 | 0.6 | 0.5 | 1.0 |
| ថៃ | 1.7 | 0.6 | 1.8 | 2.7 | 4.5 | 4.7 | 3.6 | 3.3 | 2.4 | 1.9 |
| វៀតណាម | -0.4 | 3.8 | 3.1 | 7.8 | 8.2 | - | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 0.9 | -0.7 | 1.2 | 3.9 | 1.8 | 1.5 | 1.4 | 1.8 | 2.6 | 3.6 |
| ហុងកុង | -1.3 | -3.0 | -2.6 | -0.4 | 1.1 | 2.2 | 2.3 | 2.2 | 1.7 | 1.3 |
| កូរ៉េខាងត្បូង | 4.4 | 2.7 | 3.5 | 3.5 | 2.8 | 2.4 | 2.5 | 2.4 | 2.0 | 2.4 |
| តៃវ៉ាន់ | -0.01 | -0.2 | -0.3 | 1.6 | 2.3 | 0.6 | -0.3 | -0.1 | 1.0 | 0.3 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | 0.0 | | | | |
| អឺរ៉ូ-១២ | 2.6 | 2.2 | 2.1 | 2.2 | 2.2 | 2.1 | 2.1 | 1.8 | 1.9 | 1.9 |
| ជប៉ុន | -0.6 | -0.9 | -0.3 | Nil | -0.3 | 0.5 | 0.6 | 0.3 | -0.1 | -0.1 |
| សហរដ្ឋអាមេរិក | 2.8 | 1.6 | 2.3 | 2.7 | 3.4 | 3.2 | 3.3 | 1.9 | 2.4 | 2.7 |

*Sources: International Monetary Fund, Economist and National Institute of Statistics*

*តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០១-២០០៧ (មធ្យមភាគតាមការិយបរិច្ឆេទ)*

| | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2006 | | 2007 | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q3 | Q4 | Q1 | Q2 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា (រៀល) | 3916.3 | 3912.1 | 3973 | 4016.3 | 4092.5 | 4103.2 | 4125 | 4111.3 | 4046.7 | 4075.4 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 10,261 | 9311 | 8577 | 8938 | 9705 | 9134 | 9122 | 9125 | 9107 | - |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.80 | 3.80 | 3.80 | 3.80 | 3.79 | 3.67 | 3.67 | 3.62 | 3.50 | 3.43 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.79 | 1.79 | 1.74 | 1.69 | 1.66 | 1.59 | 1.58 | 1.56 | 1.53 | 1.52 |
| ថៃ (បាត) | 44.4 | 42.9 | 41.5 | 40.2 | 40.2 | 37.9 | 37.7 | 36.5 | 33.9 | 32.5 |
| វៀតណាម (ដុង) | 14,725 | 15,280 | 15,510 | - | 15,859 | 15,994 | 16,015 | 16,077 | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន (យ៉ន់) | 8.28 | 8.28 | 8.28 | 8.28 | 8.19 | 7.97 | 7.97 | 7.86 | 7.76 | 7.68 |
| ហុងកុង (ដុល្លារហុងកុង) | 7.80 | 7.80 | 7.78 | 7.79 | 7.78 | 7.77 | 7.78 | 7.78 | 7.81 | 7.82 |
| កូរ៉េខាងត្បូង (វ៉ុន) | 1291 | 1251 | 1192 | 1145 | 1024 | 955 | 955 | 938 | 939 | 929 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 33.8 | 34.5 | 34.4 | 33.6 | 32.1 | 32.5 | 32.8 | 32.8 | 32.9 | 33.1 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 1.12 | 1.06 | 0.89 | 0.80 | 0.80 | 0.80 | 0.78 | 0.78 | 0.76 | 0.74 |
| ជប៉ុន (យ៉េន) | 121.5 | 125.4 | 115.9 | 108.2 | 110.2 | 116.4 | 116.3 | 117.8 | 119.4 | 120.8 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

*តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០១-២០០៧ (មធ្យមភាគតាមការិយបរិច្ឆេទ)*

| | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2006 | | 2007 | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q3 | Q4 | Q1 | Q2 |
| ពោត (US No. 2) - US ($/តោន) | 81.18 | 89.98 | 95.42 | 110.65 | 89.19 | 111.04 | 108.67 | 140.18 | 154.33 | 146.10 |
| ប្រេងឆា- អឺរ៉ុបពាយព្យ ($/តោន) | 259.13 | 353.91 | 402.03 | 427.47 | 381.32 | 433.85 | 446.85 | 494.92 | 552.06 | 691.44 |
| អង្ករ (Thai 100%B) – បាងកក ($/តោន) | 160.81 | 178.59 | 182.22 | 221.67 | 262.88 | 282.00 | 289.91 | 279.10 | 294.17 | 283.89 |
| សណ្តែកសៀង (US No. 1) – US ($/តោន) | 163.89 | 182.58 | 218.86 | 262.03 | 224.25 | 213.88 | 207.38 | 230.17 | 255.33 | 259.95 |
| ប្រេងឆៅ-ឌូបៃ ($/ធុង) | 22.8 | 23.9 | 26.8 | 33.5 | 50.14 | 61.58 | 67.00 | 56.39 | 54.21 | 65.41 |
| សាំង – US Gulf Coast (សេន/លីត្រ) | 19.5 | 19.1 | 23 | 30.9 | 42.19 | 47.70 | 52.70 | 41.02 | 41.71 | 57.93 |
| ម៉ាស៊ូត (ស្តង់ដ័រតិច លេខ២) – US Gulf Coast (សេន/លីត្រ) | 18.72 | 17.85 | 21.63 | 29.48 | 44.35 | 51.35 | 55.66 | 46.11 | 45.61 | 53.90 |

*Sources: Food and Agriculture Organisation and US Energy Information Administration.*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទី២ ២០០៧ គំរោងវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ បានអនុម័ត មានចំនួនថយចុះយ៉ាងខ្លាំងធៀបនឹងត្រីមាសមុន គឺធ្លាក់ចុះ ៦២% មកត្រឹម ១៩១,៣លានដុល្លារ ។ គំរោងចំនួន ២៣ កំពុងស្នើសុំការអនុមតិ ដែលវាមានចំនួនតិចជាងត្រីមាសមុន ២ គំរោង ។ ជាទូទៅ សេវាកម្ម ជាវិស័យមួយដែលមានចំណែកធំជាងគេ នៅក្នុងតំលៃអនុមតិសរុប ។ នៅត្រីមាសទី២ វិស័យនេះ ធ្លាក់ចុះ ៥៩% មកត្រឹម ១៣៧,៩លានដុល្លារ សំរាប់ ៣គំរោង ។ ក្នុងនោះ តំលៃអនុមតិសេវាទូរគមនាគមន៍ មាន ៧០លានដុល្លារ (១ គំរោង) និង វិស័យទេសចរណ៍ មាន ៥៤,៩លានដុល្លារ (១ គំរោង) ។ ឧស្សាហកម្ម ជាវិស័យសំខាន់បន្ទាប់ នៅក្នុងគំរោងវិនិយោគសរុបបានអនុម័ត ។ នៅត្រីមាសទី២ ឧស្សាហកម្មធ្លាក់ចុះ ៦៤% មកត្រឹម ៥១,២លានដុល្លារសំរាប់ ១៩គំរោង ដែលក្នុងនោះ វិស័យកាត់ដេរ មាន ៩គំរោង និងមានតំលៃ ២៤,៣លានដុល្លារ រឺធ្លាក់ចុះ ៣៤% ។ ទោះបីជា កសិកម្មផ្តល់ការងារដល់ប្រជាជនដល់ទៅ ៨០% ប៉ុន្តែវិនិយោគនៅក្នុងវិស័យនេះ មិនត្រូវបានធ្វើការអភិវឌ្ឍន៍ទេ ។ ក្នុងចំនោម ២៣ គំរោងបានអនុម័ត មានតែ ១គំរោងប៉ុណ្ណោះដែលផ្តោតលើកសិកម្ម រឺឯកសិ-ឧស្សាហកម្ម មានតំលៃ ២,១លានដុល្លារ រឺធ្លាក់ចុះ ៨៩% ធៀបនឹងត្រីមាសមុន ។ វិស័យទាំងបី ត្រូវការកម្មករបន្ថែមចំនួន ២៤.៦៧០នាក់ (ថយចុះ ៣០% ធៀបនឹងត្រីមាសមុន) ។ ឧស្សាហកម្មនឹងផ្តល់ការងារថ្មី ៩៣% សេវាកម្ម ៦,០% និង កសិកម្ម ១,០% ។

សកម្មភាពសំណង់ជាច្រើន បានលេចជារូបរាងនៅរាជធានីភ្នំពេញ និងតំបន់ជុំវិញទីក្រុង ដើម្បីកាត់បន្ថយភាពចង្អៀតតាន់តាប់ក្នុងទីក្រុងនាពេលថ្មីៗនេះ ។ បច្ចុប្បន្ន ផ្ទះល្វែងត្រូវបានសាងសង់ច្រើនជាង ផ្ទះនិងភូមិគ្រឹះ ។ នៅត្រីមាសទី២ ២០០៧ គំរោងសាងសង់សរុបបានអនុម័តនៅភ្នំពេញ មាន ១៦០,១លានដុល្លារ រឺកើន ៧៧% ធៀបនឹង ត្រីមាសទី១ ។ ការអនុមតិសាងសង់ផ្ទះនិងភូមិគ្រឹះ បានកើនពីរដង ដល់ ២២,៨លានដុល្លារ ខណៈពេលដែល សំណង់ផ្ទះល្វែង បានថយចុះ ៤២% មកត្រឹម ៣៥លានដុល្លារ ។ ធៀបនឹងត្រីមាសដូចគ្នា ២០០៦ គំរោងសាងសង់សរុបបានអនុម័តនៅភ្នំពេញ កើនឡើង ៩៥% ក្នុងនេះ សំណង់ផ្ទះល្វែងថយចុះ ៣២% រឺឯសំណង់ផ្ទះនិងភូមិគ្រឹះ កើនឡើងមួយជាបួន ។

ឱនភាពពាណិជ្ជកម្មនៅកម្ពុជា មានសភាពយ៉ាប់យ៉ឺនខ្លាំង គឺកើនបីដងធៀបនឹងត្រីមាសមុន (២០៨,១លានដុល្លារ) ។ ការនាំចេញ ធ្លាក់ចុះបន្តិច រីឯការនាំចូល កើនច្រើនគួរសម ។ ការនាំចេញ ធ្លាក់ចុះរហូតចាប់ពីត្រីមាសទី៣ ២០០៦ ។ នៅត្រីមាសទី២ ២០០៧ ការនាំចេញសរុបមាន ៧០៥,០លានដុល្លារ រឺធ្លាក់ចុះ ០,៤% ធៀបត្រីមាសមុន ។ ការនាំចេញឈើ ធ្លាក់ចុះ ៧,៩% មកត្រឹម ១,៩លានដុល្លារ រីឯការនាំចេញត្រី ធ្លាក់ចុះ ៣៨% មកត្រឹម ០,៤លានដុល្លារ និង ការនាំចេញកៅស៊ូ ធ្លាក់ចុះ ១៨% មកត្រឹម ៦,៩លានដុល្លារ ។ ការនាំចេញអង្ករមាន ០,២លានដុល្លារ រឺធ្លាក់ចុះ ៦៩% ធៀបនឹងត្រីមាសមុន ។ ប៉ុន្តែ ការនាំចេញក្នុងវិស័យកាត់ដេរកើន ១,៦% ដល់ ៦៨៨,២លានដុល្លារ ក្នុងនោះសំលៀកបំពាក់មាន ៩៦% និង ស្បែកជើង ២,៨% នៃផលិតផលកាត់ដេរនាំចេញសរុប ។ នៅត្រីមាសទី២ ការនាំចេញផលិតផលកាត់ដេរទៅសហរដ្ឋអាមេរិកធ្លាក់ចុះ ៩,៦% មកត្រឹម ៤៥១,២លានដុល្លារ រីឯការនាំចេញទៅសហគមន៍អឺរ៉ុប កើនឡើង ៥៣% ដល់ ១៦៣,១លានដុល្លារ ។ ការនាំចេញផលិតផលកាត់ដេរមានកំណើន ៨,៨% ធៀបនឹងត្រីមាសដូចគ្នាមួយឆ្នាំមុន។

ការនាំចូលសរុបនៅត្រីមាសទី២ ២០០៧ កើន ១៦% ធៀបនឹងត្រីមាសមុន ដល់ ៩៩១,៦លានដុល្លារ ។ ការនាំចូល ម្ហូបអាហារ ភេសជ្ជៈ និង ថ្នាំជក់ កើន ២២% ដល់ ៥១,៦លានដុល្លារ ដែលក្នុងនោះថ្នាំជក់មាន ៦០% និងគ្រឿងបរិភោគ ២២% ។ ការនាំចូលស៊ីម៉ង់ត៍មានកំណើន ២៦% ដល់ ២១,៦លានដុល្លារ ស្របពេលដែលការនាំចូលដែក ធ្លាក់ចុះ ២៣% មកត្រឹម ១៣,៥លានដុល្លារ ។ ទោះជាថ្លៃសាំងជាមធ្យមនៅទីផ្សារ បានកើនដល់ ៣.៨៧៦ រៀល/លីត្រ រឺកើន ៣,៥% ក៏បរិមាណសាំងនាំចូលនៅតែបន្តកើនឡើង គឺកើន ២៨% ដល់ ៦៥.៣២០តោន រឺស្មើនឹង ២០,២លានដុល្លារ ។ ម៉ាស៊ូតនាំចូលមាន ១៣៤.៤៣០តោន រឺកើន ១៣% ធៀបនឹងត្រីមាសមុន ហើយមានតំលៃស្មើនឹង ៣៦,៦លានដុល្លារ ។ ធៀបនឹងត្រីមាសដូចគ្នា ២០០៦ ការនាំចូលសាំង និងម៉ាស៊ូត កើន ៦៤% និង ១៧% ។

នៅត្រីមាសទី២ ២០០៧ ភ្ញៀវបរទេសមកដល់ប្រទេសកម្ពុជា មានសរុប ៤២៤.៥០០នាក់ រឺថយចុះ ២៣% ធៀបត្រីមាសមុន ។ ភ្ញៀវមកដល់តាមផ្លូវអាកាសធ្លាក់ចុះ ២៦% មកត្រឹម ២៧៥.៦០០នាក់ ។ ដោយឡែកភ្នំពេញទទួលបាន ៤៤% និង សៀមរាប បាន ៥៦% នៃភ្ញៀវសរុបមកដល់តាមផ្លូវអាកាស ។ ភ្ញៀវមកដល់តាមផ្លូវគោកមាន ៣៤% នៃភ្ញៀវបរទេសសរុប និង ភ្ញៀវធ្វើដំណើរតាមជើងទឹកមាន ១,៤% ។ ខេត្តសៀមរាប មានភ្ញៀវសរុប ២១៥.៦៣៤នាក់ រឺថយចុះ ៤៦% ធៀបត្រីមាសមុន ។ ភ្ញៀវបរទេសមកក្នុងគោលបំណង សំរាកលំហែ មានចំនួន ៣៥.២១៦នាក់ រឺធ្លាក់ចុះ ២៨% ធៀបនឹងត្រីមាសមុន រីឯភ្ញៀវមកក្នុងគោលបំណងជំនួញ កើន ១៤% ដល់ ៣៤.៨០៨នាក់ ។ កូរ៉េខាងត្បូង គឺជាប្រទេសនាំមុខគេខាងភ្ញៀវធ្វើដំណើរមកកម្ពុជា (៧៨.១០៨នាក់) ។

## ហិរញ្ញវត្ថុសាធារណៈ

ថវិការដ្ឋសំរាប់ត្រីមាសទី២ មានទិន្នន័យត្រឹមតែខែឧសភាប៉ុណ្ណោះ ។ ក្នុងអំឡុង២ខែនេះ ការប្រមូលចំណូលសរុបមាន ៦៧៦.៦ពាន់លានរៀល រឺកើន ៥៣% ធៀបនឹងអំឡុងពេលដូចគ្នា ២០០៦ ។ ចំណូលពន្ធកើន ៦៤% ដល់ ៥៨៥.១ពាន់លានរៀល ។ ពន្ធក្នុងស្រុកមាន ៧៣% នៃចំណូលពន្ធសរុប ដែលក្នុងនោះ ២០% បានមកពី ការយកពន្ធលើប្រាក់ចំនេញ ពន្ធលើប្រាក់ចំណូល និងពន្ធលើតំលៃលើស និង ៣១% បានមកពីពន្ធលើតំលៃបន្ថែម (VAT) ។ ពន្ធលើពាណិជ្ជកម្មអន្តជាតិមាន ២៦% នៃចំណូលពន្ធសរុប ក្នុងនោះពន្ធនាំចូលមាន ២៣% និង ពន្ធនាំចេញ ៣% ។ ចំណូលមិនមែនពន្ធ ដូចជា ចំណូលពីអចលនទ្រព្យ និង ការលក់ទំនិញនិងសេវា កើន ៧,២% ដល់ ៨៧,០ពាន់លានរៀល ធៀបនឹងអំឡុងពេលដូចគ្នា ២០០៦ ។ ចំណូលពីអចលនទ្រព្យមាន ១០% ការលក់ទំនិញនិងសេវា ៨១% និង ចំណូលមិនមែនពន្ធផ្សេងៗទៀតមាន ៨,៥% នៃចំណូលមិនមែនពន្ធសរុប ។

នៅពីរបីត្រីមាសកន្លងទៅនេះ ចំណូលក្នុងស្រុកមានការកើនឡើងជាលំដាប់ និង ចំណាយថវិកាមានការប្រែប្រួលចុះឡើង ។ នៅខែមេសា-ឧសភា ២០០៧ ចំណាយថវិកា កើន ១,៩% ដល់ ៦៨០,២ពាន់លានរៀល ធៀបនឹងអំឡុងពេលដូចគ្នា ២០០៦ ។ ចំណាយចរន្តមាន ៤៦៣,៦ពាន់លានរៀល រឺកើន ១៩% ។ ក្នុងនោះ ចំណាយលើប្រាក់បៀវត្សរ៍ មាន ១៦៤,៣ពាន់លានរៀល រឺកើន ១៤% និង ចំណាយមិនមែនប្រាក់បៀវត្សរ៍មានកំណើន ៨,៣% ដល់ ២៨៤,៣ ពាន់លានរៀល ។ ចំណាយមិនមែនប្រាក់បៀវត្សរ៍ រួមមាន ៣៥% លើការទិញនិងថែទាំសំភារៈការិយាល័យ ៦,៤% លើការជួលនិងជួសជុលអគារ

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

៣,៩% លើការប្រាក់នៃបំណុលពីខាងក្រៅ និង ៤២% លើឧបត្ថម្ភធននិងជំនួយសង្គម ។ ចំណាយចរន្ត រួមមាន ចំណាយមូលធន ដែលថយចុះ ២២% មកត្រឹម ២១៦,៥ពាន់លានរៀល ធៀបនឹងពេលដូចគ្នា ២០០៦ ។ ចំណាយមូលធនទទួលបានមូលនិធិ ៧០% ពីប្រភពខាងក្រៅ និង ៣០% ពីប្រភពខាងក្នុង។

## អតិផរណា និងអត្រាប្តូរប្រាក់

នៅត្រីមាសទី២ ថ្លៃទំនិញទូទៅកើន ៤,៦% ធៀបនឹងត្រីមាសដូចគ្នា ២០០៦ ។ ថ្លៃម្ហូបអាហារ ភេសជ្ជៈ និង ថ្នាំជក់កើន ៧,២% ហើយថ្លៃដឹកជញ្ជូន និងទូរគមនាគមន៍កើន ៤,៩% ។ ថ្លៃសំលៀកបំពាក់និងស្បែកជើងកើន ២,៨% គ្រឿងប្រើប្រាស់នៅក្នុងគេហដ្ឋាន ២,៧% ចំណាយលើផ្ទះស្នាក់នៅនិងទឹកភ្លើង ២,៦% និង តំហែទាំសុខភាព ១,៥%។ ថ្លៃដឹកជញ្ជូននិងទូរគមនាគមន៍ កើនឡើងដោយសារមកពីការឡើងថ្លៃប្រេងឥន្ធនៈ ។

នៅត្រីមាសទី២ ប្រាក់រៀល ឡើងថ្លៃ ០,៨% ទល់នឹងដុល្លារUS បើធៀបនឹងត្រីមាសដូចគ្នា ២០០៦ ។ ប្រាក់រៀល ប្តូរបានជាមធ្យម ៤០៧៥,៤ រៀល/ដុល្លារUS ។ ទល់នឹងប្រាក់ដុងវៀតណាម ប្រាក់រៀលឡើងថ្លៃ ០,៨% ដោយប្តូរបាន ២៤,៨រៀល/១០០ដុង ហើយទល់នឹងប្រាក់បាតថៃ ប្រាក់រៀលធ្លាក់ថ្លៃ ៩,៣% ដោយប្តូរបាន ១១៨,១ រៀល/បាត ។

## ការវិវត្តន៍រូបិយវត្ថុ

ពីខែមិថុនា ២០០៦-មិថុនា ២០០៧ ឥណទានក្នុងស្រុក កើន ៤៥% ដល់ ៣១៣៦,០ពាន់លានរៀល ។ ក្នុងនោះ ឥណទានរដ្ឋាភិបាល កើន ៨,៨% ដល់ ២៩៧,៦ពាន់លានរៀល និង ឥណទានឯកជន កើន ៥១% ដល់ ៤៥៣៨,៧ ពាន់លានរៀល ។ ប្រាក់បញ្ញើរដ្ឋាភិបាលបន្តកើនឡើងជាលំដាប់ ដោយកើន ៥៤% ដល់ ១៧០០,២ពាន់លានរៀល ។ ទន្ទឹមនឹងគ្នានេះ "បំណុលផ្សេងៗ" តំណាងអោយបំណុលធនាគារជាតិបានថយចុះ ១៨% មកត្រឹម ៣៣០៧,៨ ពាន់លានរៀល ។ នៅខែមិថុនា ២០០៧ ឥណទានក្នុងស្រុក និង "បំណុលផ្សេងៗ" ធ្វើអោយឥណទានក្នុងស្រុកសុទ្ធ មានលទ្ធផលអវិជ្ជមាន រឺ -១៧១,៧ ពាន់លានរៀល ប៉ុន្តែវាមានកំណើន ៧៣% បើធៀបនឹងខែដូចគ្នា ២០០៦ ។ ទ្រព្យសកម្មបរទេសសុទ្ធកើន ៣៥% ដល់ ៩០៤៧,៩ពាន់លានរៀល ។

នៅខែមិថុនា ប្រតិបត្តិការពាក់ព័ន្ធនឹងទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធ បានធ្វើឱ្យរូបិយវត្ថុទូទៅសរុប (M2) កើន ៤៧% ដល់ ៨៨៧៦,១ពាន់លានរៀល ធៀបនឹងអំឡុងពេលដូចគ្នាមួយឆ្នាំមុន ។ រូបិយវត្ថុទូទៅ M2 រួមមាន រូបិយវត្ថុ M1 និងរូបិយវត្ថុផ្សេងៗ ។ រូបិយវត្ថុ M1 មាន ១៧៤៨,៤ពាន់លានរៀល រឺកើន ១៦% ក្នុងនោះ រូបិយវត្ថុនៅក្រៅធនាគារ កើន ១៥% ដល់ ១៦៨១,៩ពាន់លានរៀល ហើយបញ្ញើចរន្តមានកំណើន ២៧% ដល់ ៦៦,៥ពាន់លានរៀល ។ ប្រាក់បញ្ញើមានកាលកំណត់ និងប្រាក់បញ្ញើសន្សំបានថយចុះ ១៣% មកត្រឹម ៩៨,៥ពាន់លានរៀល ខណៈពេលដែលប្រាក់បញ្ញើជារូបិយវត្ថុបរទេសកើន ៥៩% ដល់ ៧០២៩,២ពាន់លានរៀល ហើយខ្ទង់ទាំងនេះ ជារូបិយវត្ថុផ្សេងៗ ដែលកើន ៥៧% ដល់ ៧១២៧,៧ពាន់លានរៀល ។

គិតត្រឹមខែមិថុនា ២០០៧ ធនាគារជាតិនៃកម្ពុជាបានតំឡើងប្រាក់បំរុងរបស់ខ្លួនរហូតដល់ ៥១៤,៥ពាន់លានរៀល រឺកើន ២៤% ធៀបនឹងខែមិថុនា ២០០៦ ។ ប្រាក់បំរុងជារូបិយវត្ថុបរទេសរបស់កម្ពុជា មានតំលៃស្មើនឹង ការនាំចូលទំនិញ ៣,៧ខែ ។

## ស្ថានភាពភាពក្រីក្រ និងប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ពលករងាយរងគ្រោះ

នៅខែសីហា ២០០៧ ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ពលករងាយរងគ្រោះចំនួន ១០ក្រុម កើន ២៣% ធៀបនឹងអំឡុងពេលដូចគ្នា ២០០៦ ។ ទោះយ៉ាងនេះក្តី ប្រាក់ចំណូលរបស់កម្មករសំណង់គ្មានជំនាញ កម្មករកាត់ដេរ និងអ្នកបំរើតាមភោជនីយដ្ឋាន បានថយចុះបន្តិច ។

ប្រាក់ចំណូលសុទ្ធរបស់អ្នកលក់បន្លែតូចតាច បានកើន ៧៥% ដល់ ៩១១៦រៀល នៅខែសីហា ២០០៧ ធៀបនឹងខែដូចគ្នា ២០០៦ ។ តួលេខនេះគឺជាកំណើនខ្ពស់បំផុត គិតតាំងពីពេលចាប់ធ្វើអង្កេតនៅឆ្នាំ១៩៩៨ ។ ទិន្នន័យបានមកពី វិទ្យាស្ថានជាតិស្ថិតិ បង្ហាញថា ថ្លៃបន្លែស្រស់ កើន ៣៦% ខណៈពេលដែលថ្លៃទំនិញភាគច្រើន នៅភ្នំពេញបានកើនតែ ៥,២% ប៉ុណ្ណោះក្នុងរយៈមួយឆ្នាំដល់ខែសីហា ២០០៧ ។ កំណើនថ្លៃទំនិញនេះ ក៏ធ្វើអោយមានការកើនចំណូលដល់ អ្នកលក់បន្លែតូចតាចផងដែរ ។ អ្នកលក់បន្លែតូចតាច ៩៥% ឆ្លើយថាចំណូលពួកគេអាចជួយធ្វើឱ្យជីវភាពគ្រួសារបានប្រសើរឡើង ប៉ុន្តែមិនបានច្រើនប៉ុន្មានទេ ។ ពួកគេ ២០% សន្សំប្រាក់បានមួយចំនួន និង ៨០% ផ្សេងទៀតមិនបានសន្សំប្រាក់ទាល់តែសោះ ។

នៅខែសីហា ចំណូលប្រចាំថ្ងៃរបស់អ្នករើសអេតចាយ កើនដល់ ៦០៣៨ រៀល រឺកើន ៤២% ច្រើនជាងអំឡុងពេលដូចគ្នា មួយឆ្នាំមុន ។ អ្នករើសអេតចាយ ៦៦% បានរាយការណ៍ថា ចំណូលពួកគេកើនឡើង ដោយសារតែអេតចាយឡើងថ្លៃ ហើយវាជាប្រាក់ចំណូលខ្ពស់ជាងគេដែរ ចាប់តាំងពីអង្កេតបានចាប់ផ្តើម ។ អ្នករើសអេតចាយ ៧០% ជាជនចំណាកស្រុកមកពីជនបទ និង ៣០% ផ្សេងទៀតជាអ្នកនៅទីក្រុងក្បែរកន្លែងចាក់សំរាម ។ ទោះបីជាចំណូលរបស់អ្នករើសអេតចាយបានកើនឡើង ប៉ុន្តែមាន ៤៣% បានរាយការណ៍ថា គ្រួសារខ្លួនបានជំពាក់បំណុលគេ ។ នេះបានន័យថា ចំណូលពួកគេមិនគ្រប់គ្រាន់សំរាប់ទ្រទ្រង់ជីវភាពគ្រួសារទេ ។ យោងតាមអង្កេត ក្មេងៗជាច្រើនបានដើរតាមឪពុកម្តាយ រឺសាច់ញាតិទៅកាយគំនរសំរាមដើម្បីបានចំណូល ជាពិសេសដើម្បីទិញសំភារៈសិក្សា ហើយចំណូលដែលនៅសល់ ពួកគេសន្សំទុកសំរាប់ក្រុមគ្រួសារ ។

បន្ទាប់ពីការធ្លាក់ចុះនៅឆ្នាំ២០០៦ ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់អ្នករត់ម៉ូតូឌុប បានកើនយ៉ាងខ្លាំង ចាប់តាំងពីដើមឆ្នាំ២០០៧មក ។ ប្រាក់ចំណូលបានកើន ៣៣% បើធៀបនឹងអំឡុងពេលដូចគ្នា ២០០៦ ដែលកំណើននេះបណ្តាលមកពីកំរៃដឹកអ្នកដំណើរមានការកើនឡើង ។ ចំពោះអ្នករត់ម៉ូតូឌុបបានផ្តល់សំភាសន៍ មាន ៧៣% ប្រាប់ថា ចំណូលពួកគេ គឺគ្រប់គ្រាន់សំរាប់តែចំណាយក្នុងគ្រួសារប៉ុណ្ណោះ ដូចនេះ ពួកគេមិនអាចសន្សំប្រាក់សំរាប់បង្កើតមុខរបរផ្សេងទៀតបានទេ ។ ផ្ទុយទៅវិញ អ្នករត់ម៉ូតូឌុប ២៧% ប្រាប់ថាអាចសន្សំប្រាក់បាន ។ អ្នករត់ម៉ូតូឌុប ៧៣% បានចំណាយពី ១០ ទៅ ១៥ដុល្លារក្នុងមួយខែ សំរាប់ជួលផ្ទះស្នាក់នៅ ក្នុងអំឡុងពេលមកធ្វើការនៅភ្នំពេញ ហើយ ២៧% ផ្សេងទៀត មានទីលំនៅក្នុងក្រុង រឺនៅជាយក្រុង ។

ពីខែសីហា ២០០៦-ខែសីហា ២០០៧ ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់កម្មករសំណង់មានជំនាញ កើន ២៤% ដល់ ១១.៧២៣រៀល ។ កម្មករទាំងនោះ ៩៧% និយាយថា ដោយសារតែការសាងសង់មានចំនួនកាន់តែច្រើន ពួកគេអាចរកចំណូលក្នុងចន្លោះពី ៨០០០រៀល ទៅ ២៥.០០០ រៀល/ថ្ងៃ អាស្រ័យទៅតាមបទពិសោធន៍ការងារពួកគេម្នាក់ៗ ។ បន្ទាប់ពីចំណាយទៅលើម្ហូបអាហារ កម្មករមួយចំនួន មានសល់ប្រាក់ខ្លះសំរាប់ធ្វើជា

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

ដើមទុន ដើម្បីបង្កើតមុខរបរផ្សេងទៀត និងលើកកំពស់ជីវភាពគ្រួសារ ។ កម្មករសំណង់មានជំនាញភាគច្រើនធ្វើការជាមធ្យម ៧ខែ/ឆ្នាំ នៅភ្នំពេញ ហើយស្ទើរតែ ៣០ថ្ងៃ/ខែ ។ នៅអំឡុងពេលដូចគ្នា គិតចាប់ពីខែសីហា ឆ្នាំ២០០៦ ចំណូលរបស់កម្មករសំណង់គ្មានជំនាញបានថយចុះ ៧,៨% មកត្រឹម ៥៩០០រៀល ។ ការថយចុះនេះ អាចបណ្តាលមកពីការកើនចំនួនកម្មករគ្មានជំនាញធ្វើចំណាកស្រុកមកពីជនបទ ។ ពួកគេធ្វើការប្រហែល ១៥ថ្ងៃ/ខែ ហើយពួកគេត្អូញត្អែរថា មិនអាចសន្សំប្រាក់បានច្រើនទេ ដោយសារត្រូវចំណាយលើម្ហូបអាហារប្រចាំថ្ងៃ មិនតែប៉ុណ្ណោះនៅឆ្នាំនេះ ទំនិញគ្រប់មុខសុទ្ធតែឡើងថ្លៃ ។ ពួកគេភាគច្រើន មកពីបណ្តាខេត្តផ្សេងៗ ហើយ ៤២% នៅលីវ និង ៥០% មានអាយុតិចជាង ២៥ឆ្នាំ និងទទួលការសិក្សាត្រឹមកំរិតបឋមសិក្សា។

នៅខែសីហា ចំណូលប្រចាំថ្ងៃរបស់អ្នកធាក់ស៊ីក្លូមានចំនួន ៧១២៦រៀល ដែលកើន ១៨% ធៀបនឹងខែដូចគ្នា ២០០៦ ។ ការបន្ថែមម៉ោងធ្វើការ គឺជាប្រភពដ៏សំខាន់នៃការកើនចំណូលរបស់ពួកគេ ។ អង្កេតរកឃើញថា អ្នកធាក់ស៊ីក្លូធ្វើការច្រើនជាង ១១ម៉ោង/ថ្ងៃ ។ ទោះបីជាមានកំណើនចំណូល ប៉ុន្តែអ្នកធាក់ស៊ីក្លូ ៧០% បាននិយាយថា ចំណូលនេះមិនអាចផ្គត់ផ្គង់គ្រួសារបានគ្រប់គ្រាន់ទេ ។ អ្នកធាក់ស៊ីក្លូភាគច្រើន ជាជនចំណាកស្រុកបណ្តោះអាសន្នមកពីជនបទ ហើយស្ទើរតែទាំងអស់គ្នា បានស្នាក់នៅតាមផ្ទះរបស់ម្ចាស់ស៊ីក្លូ។

បើធៀបនឹងខែសីហា ២០០៦ ចំណូលប្រចាំថ្ងៃពិតរបស់កម្មករកាត់ដេរបានថយចុះ ២,៥% មកត្រឹម ៩០៣៣រៀល ទោះបីជាចំណូលចារឹកបានកើនឡើង ២,២% ។ នៅខែសីហា កម្មករកាត់ដេរ ចំណាយប្រហែល ៤០ដុល្លារ លើម្ហូបអាហារ ផ្ទះស្នាក់នៅ និងគ្រឿងសំអាង ។ ចំណាយនេះកើន ២១% ធៀបនឹងអំឡុងពេលដូចគ្នា ឆ្នាំ២០០៦ ។ កម្មករកាត់ដេរភាគច្រើន អាចសន្សំប្រាក់ជាមធ្យម ២៧ដុល្លារ/ខែ ។ ពួកគេច្រើនជាង ៩០% ជាជនមកពីតាមបណ្តាខេត្តនានាជុំវិញប្រទេស ហើយភាគច្រើនបានចូលធ្វើការនៅតាមរោងចក្រ ដោយសារមានការណែនាំពីសាច់ញាតិ រឺអ្នកជិតខាង ដែលមានបទពិសោធន៍ធ្វើការនៅរោងចក្រ ។ កម្មករកាត់ដេរទាំងនោះ បានជួលផ្ទះស្នាក់នៅជាមួយគ្នា ។ ពួកគេ ៤១% ជាសមាជិកសហជីពនៅរោងចក្រដែលពួកគេធ្វើការ ហើយ ៥៩% ផ្សេងទៀត មិនបានដឹងច្រើនអំពីសកម្មភាពរបស់សហជីពទេ ។

ចំណូលប្រចាំថ្ងៃរបស់អ្នកស៊ីឈ្នួលធ្វើស្រែបានកើនឡើង ១០% ធៀបនឹងអំឡុងពេលដូចគ្នា ឆ្នាំ២០០៦ ។ កំណើនចំណូលបណ្តាលមកពីការធ្វើចំណាកស្រុក ជាពិសេសពួកក្មេងៗចេញពីភូមិទៅទីក្រុងធ្វើជាកម្មករកាត់ដេរ ដែលជាហេតុនាំអោយខ្វះកំលាំងពលកម្មនៅតាមភូមិ ។ ម្យ៉ាងវិញទៀត អ្នកស៊ីឈ្នួលធ្វើស្រែ បាននិយាយថា ពួកគេមិនមានការងារជាប់លាប់ទេ ដូច្នេះចំណូលដែលបានមកមិនអាចទ្រទ្រង់គ្រួសារទាំងមូលឡើយ ទោះបីជាពួកគេបានជួយខ្លះៗក៏ដោយ ។ ពួកគេ ៤២% បានជំពាក់បំណុលគេ ហើយបំណុលភាគច្រើន គឺបានខ្ចីពីម្ចាស់ដីស្រែ ដោយត្រូវសងទៅគេវិញជាកំលាំងពលកម្មនៅរដូវធ្វើស្រែ។

*រៀបរៀងដោយ*
*ប៊ុន ដូរីណា និង ផាន់ ដាលីស*

---

## *តពីទំព័រ ២០* ព័ត៌មានថ្មីៗ ...

ការស្រាវជ្រាវ និងការងារខាងគោលនយោបាយសំខាន់ៗរបស់វិទ្យាស្ថាន CDRI ក្នុងពេលបច្ចុប្បន្ន រួមមាន:

- ការចុះស្រាវជ្រាវឆ្លងប្រទេសរួមគ្នារបស់បណ្តាញវិភាគអភិវឌ្ឍន៍ (DAN) ស្តីពីចំណាកស្រុកកំលាំងពលកម្មឆ្លងកាត់ព្រំដែនក្នុងមហាអនុតំបន់មេគង្គ ដែលបង្ហាញពីការរីកចំរើននៃទំនាក់ទំនងក្នុងបណ្តាញនៅក្នុងតំបន់នេះ ហើយនិងគំរោងបណ្តាញវិភាគអភិវឌ្ឍន៍ DAN ដែលផ្តោតលើពាណិជ្ជកម្មផលិតផលកសិកម្ម នៅក្នុងមហាអនុតំបន់មេគង្គ ។
- ការសិក្សាពីការដឹកនាំខាងនយោបាយនៅតាមមូលដ្ឋាន ដែលជាប់ទាក់ទងនឹងគោលដៅកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងការវិភាគលើ ច្បាប់រៀបចំអង្គការស្តីពីអភិបាលកិច្ចថ្នាក់ក្រោមជាតិនៅកម្ពុជា ។
- ការសិក្សាលើអភិបាលកិច្ចធនធានទឹកសំដៅកាត់បន្ថយភាពក្រីក្រ ដែលជាផ្នែកមួយ នៃកម្មវិធីកសាងសមត្ថភាពស្រាវជ្រាវលើធនធានទឹករយៈ ៥ឆ្នាំ របស់វិទ្យាស្ថាន CDRI ដើម្បីកំណត់ពីរបៀបរៀបចំខាងអភិបាលកិច្ចធនធានទឹក ដែលអាចជួយជំរុញផលិតកម្មកសិកម្មអោយមានចីរភាព និងទទួលបានទឹកសំរាប់ចែកចាយប្រើប្រាស់ស្មើភាពគ្នា ។
- ការវិភាគចំណាយនិងផលចំណេញ នៃការអភិវឌ្ឍន៍ចំការកៅស៊ូនៅកម្ពុជា ដោយពិនិត្យពីការដោះដូរផលចំណេញចុះឡើងក្នុងការអភិវឌ្ឍន៍ចំការកៅស៊ូ ។
- គំរោងរួមគ្នាមួយស្តីពី ព្រៃតំបន់ត្រូពិកសំរាប់ការកាត់បន្ថយភាពក្រីក្រ ដែលមានតាំងពីទិន្នន័យតាមគ្រួសារ រហូតដល់ការវិភាគសរុបសំរាប់ ៥ប្រទេស ដើម្បីបង្កើនការយល់ដឹងពីតួនាទីរបស់ព្រៃតំបន់ត្រូពិកក្នុងការទប់ស្កាត់ និងកាត់បន្ថយភាពក្រីក្រនៅជនបទ ។
- ការសិក្សាពីផលប៉ះពាល់នៃពាណិជ្ជកម្មទៅលើបរិស្ថាន នៅក្នុងមហាអនុតំបន់មេគង្គ ដែលបានចុះកិច្ចសន្យាប្រគល់អោយធ្វើដោយបណ្តាញចំនេះដឹងពាណិជ្ជកម្ម នៅទីក្រុងហ្សឺណែវ ។
- អង្កេតលើបរិស្ថានធម្មជាតិ និងសង្គម ធ្វើឡើងដោយវិទ្យាស្ថាន CDRI ក្នុងកិច្ចសហការជាដៃគូជាមួយ ក្រុមសិក្សារបស់ JICA ដើម្បីវាយតំលៃពីបញ្ហាខាងបរិស្ថានធម្មជាតិនិងសង្គម ជួយដល់ការសិក្សាប្លង់មេ សំរាប់ការអភិវឌ្ឍន៍វារីអគ្គិសនីនៅកម្ពុជា ។

## តារាង១. គំរោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ១៩៩៩-២០០៧

| | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | | | | 2007 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | | | | | | | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | |
| កសិកម្ម | 9.8 | 0.4 | 40.3 | 3.7 | 12.3 | 26.8 | 126.5 | 216.9 | 0.0 | 154.6 | 19.1 | 2.1 |
| ឧស្សាហកម្ម | 109.4 | 105.2 | 67.7 | 137.2 | 187.9 | 914.6 | 40.1 | 76.9 | 171.7 | 76.6 | 142.7 | 51.2 |
| កាត់ដេរ | *81.5* | *26.5* | *27.2* | *68.1* | *132.6* | *174.4* | *30.5* | *9.6* | *23.2* | *26.1* | *36.6* | *24.3* |
| សេវាកម្ម | 150.1 | 118.4 | 145.3 | 168.4 | 91.8 | 155.5 | 60.7 | 2,043.2 | 94.5 | 740.7 | 335.7 | 138.0 |
| សណ្ឋាគារ និងទេសចរណ៍ | *79.8* | *73.8* | *47.1* | *124.1* | *55.9* | *102.6* | *0.0* | *26.2* | *3.5* | *315.3* | *140.3* | *55.0* |
| សរុប | 269.2 | 224.0 | 253.3 | 309.3 | 292.0 | 1096.9 | 227.3 | 2,337.0 | 266.2 | 971.9 | 497.5 | 191.3 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| សរុប | - | - | - | - | - | - | 90.7 | 928.1 | -88.6 | 265.1 | -48.8 | -61.6 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| សរុប | -40.0 | -16.8 | 13.1 | 22.1 | -5.6 | 275.6 | -52.2 | 2331.2 | -34.1 | 715.4 | 118.9 | 91.8 |

*Including expansion project approvals. Source: Cambodian Investment Board*

## តារាង២. តំលៃគំរោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ១៩៩៩-២០០៧

| | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | | | | 2007 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | | | | | | | លានដុល្លារ | | | | | |
| ភូមិគ្រឹះ, ផ្ទះ | 16.4 | 15.9 | 23.4 | 20.0 | 30.3 | 45.5 | 10.1 | 5.7 | 7.6 | 9.7 | 10.9 | 22.8 |
| ផ្ទះល្វែង | 174.8 | 167.8 | 179.9 | 91.6 | 167.6 | 204.2 | 39.9 | 51.8 | 67.1 | 54.5 | 59.9 | 35.0 |
| ផ្សេងៗ | 14.2 | 12.6 | 16.6 | 87.3 | 65.6 | 109.1 | 17.4 | 24.7 | 20.8 | 13.9 | 19.5 | 102.2 |
| សរុប | 205.4 | 196.3 | 219.9 | 198.9 | 263.5 | 358.8 | 67.4 | 82.2 | 95.5 | 78.2 | 90.4 | 160.1 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| សរុប | - | - | - | - | - | - | -6.2 | 22.2 | 16.1 | -18.1 | 15.6 | 77.2 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| សរុប | -37.2 | -4.4 | 12.0 | -9.5 | 32.5 | 36.2 | -36.5 | -21.2 | 24.8 | 8.9 | 34.2 | 94.6 |

*Source: Department of Cadastre and Geography of Phnom Penh municipality*

## តារាង៣. ការនាំចេញ និងនាំចូល ឆ្នាំ១៩៩៩-២០០៧

| | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | | | | 2007 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | | | | | | | លានដុល្លារ | | | | | |
| ការនាំចេញសរុប | 1056.2 | 1268.2 | 1453.2 | 1708.1 | 2108.1 | 2352.8 | 603.2 | 652.5 | 807.5 | 736.7 | 707.8 | 705.0 |
| រួមមាន: សំលៀកបំពាក់ | 962.1 | 1202.2 | 1355.8 | 1628.4 | 2027 | 2253.3 | 568.5 | 632.4 | 782.0 | 716.0 | 677.5 | 688.2 |
| - ទៅសហរដ្ឋអាមេរិក | *714.1* | *840.9* | *943.4* | *1099.8* | *1270.9* | *1546.1* | *402.5* | *438.6* | *522.8* | *483.2* | *499.1* | *451.2* |
| - ទៅសហគមន៍អ៊ឺរ៉ុប | *228.1* | *323.3* | *356.3* | *414.7* | *590.8* | *503.1* | *110.6* | *142.2* | *188.1* | *160.1* | *106.3* | *163.1* |
| - ប្រទេសផ្សេងទៀត | *19.9* | *38.0* | *56.1* | *113.8* | *165.3* | *204.1* | *55.3* | *51.6* | *71.0* | *72.8* | *72.0* | *73.8* |
| កសិកម្ម | 94.2 | 66.0 | 97.3 | 79.7 | 81.2 | 99.5 | 34.7 | 20.2 | 25.5 | 20.7 | 30.3 | 16.8 |
| - កៅស៊ូ | *29.6* | *25.9* | *29.7* | *35.1* | *38.3* | 36.7 | 7.8 | 9.8 | 13.6 | 10.2 | 8.4 | 6.9 |
| - ឈើ | *32.9* | *22.3* | *16.0* | *10.2* | *11.1* | 10.3 | 2.1 | 2.3 | 2.5 | 1.7 | 2.1 | 2.0 |
| - ត្រី | *5.4* | *6.0* | *4.3* | *2.8* | *10.6* | 10.1 | 1.9 | 1.0 | 1.6 | 1.4 | 0.7 | 0.4 |
| - ផ្សេងៗ | *26.2* | *11.8* | *47.4* | *31.6* | *21.3* | 42.6 | 22.9 | 7.0 | 7.7 | 7.5 | 19.0 | 7.5 |
| ការនាំចូលសរុប | 1417.7 | 1501.4 | 1707.8 | 1824.9 | 2149.0 | 2513 | 690.7 | 774.9 | 784.3 | 807.1 | 790.9 | 911.6 |
| រួមមាន: - សាំង | - | - | 25.9 | 33.2 | 30.2 | 40.2 | 10.9 | 12.4 | 13.1 | 13.2 | 15.7 | 20.2 |
| - ម៉ាស៊ូត | - | - | 100.8 | 109.6 | 109.4 | 93.1 | 32.5 | 32.2 | 30.1 | 27.2 | 31.9 | 36.6 |
| - សំភារៈសំណង់ | - | - | 12.9 | 80.8 | 95.3 | 134.7 | 37.0 | 39.1 | 42.5 | 35.8 | 44.1 | 47.3 |
| - ផ្សេងៗ | - | - | 1568.2 | 1601.3 | 1914.0 | 2245 | 610.3 | 691.2 | 698.5 | 731.0 | 699.2 | 807.5 |
| ជញ្ជីងពាណិជ្ជកម្ម | -361.5 | -233.2 | -254.6 | -116.8 | -40.9 | -160.1 | -87.5 | -122.4 | 23.2 | -70.4 | -83.1 | -208.1 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | - | - | - | - | - | - | -5.4 | 11.2 | 23.7 | -8.4 | -5.4 | 1.6 |
| ការនាំចេញសរុប | - | - | - | - | - | - | -6.4 | 8.2 | 23.7 | -8.8 | -3.9 | 0.4 |
| ការនាំចូលសរុប | - | - | - | - | - | - | -0.03 | 12.2 | -1.6 | 5.9 | -2.0 | 15.5 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | 74.0 | 24.9 | 12.8 | 20.1 | 24.5 | 11.2 | 27.8 | 27.1 | 10.2 | 19.1 | 19.2 | 8.8 |
| ការនាំចេញសរុប | 12.2 | 20.1 | 14.6 | 17.5 | 23.4 | 11.6 | 30.3 | 26.7 | 10.6 | 14.3 | 17.3 | 8.0 |
| ការនាំចូលសរុប | 14.6 | 5.9 | 13.7 | 6.9 | 17.8 | 16.9 | 32.6 | 15.6 | 20.9 | 16.8 | 14.5 | 17.8 |

*Import data include tax-exempt imports. Sources: Department of Trade Preferences Systems, MOC and Customs and Excise Department, MEF (web site)*

## តារាង៤. ចំនួនអ្នកដំណើរមកដល់ក្នុងប្រទេសកម្ពុជា ឆ្នាំ១៩៩៩-២០០៧

| | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | | | | 2007 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | | | | | | | អ្នកដំណើរពាន់នាក់ | | | | | |
| តាមផ្លូវអាកាស | 351.7 | 408.4 | 523.0 | 456.0 | 626.1 | 856.5 | 275.4 | 204.4 | 224.2 | 325.0 | 373.6 | 275.6 |
| តាមផ្លូវគោក និងទឹក | 114.7 | 196.5 | 263.5 | 245.0 | 428.9 | 565.1 | 181.9 | 153.6 | 146.4 | 191.0 | 177.2 | 148.9 |
| សរុប | 466.4 | 604.9 | 786.5 | 701.1 | 1055.0 | 1421.6 | 457.3 | 358.0 | 370.6 | 516.0 | 550.8 | 424.5 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| សរុប | - | - | - | - | - | - | 9.9 | -21.7 | 4.1 | 39.2 | 6.7 | -22.9 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| សរុប | 26.8 | 29.7 | 30.0 | -10.9 | 50.5 | 34.7 | 20.2 | 21.2 | 14.7 | 24.1 | 20.4 | 19.2 |

*Source: Ministry of Tourism.*

## តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានជាសាច់ប្រាក់ ឆ្នាំ១៩៩៨-២០០៦ (ពាន់លានរៀល)

| | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 Q1* | Q2* | Q3* | Q4* | 2007 Q1* | Q2 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំណូលសរុប | 1528 | 1530 | 1744 | 1764 | 2126 | 2625 | 595.9 | 731.5 | 732.2 | 1199.6 | 824.9 | 676.6 |
| ចំណូលចរន្ត | - | 1521 | 1728 | 1733 | 2107 | 2474 | 593.2 | 726.9 | 716.8 | 844.9 | 824.9 | 676.6 |
| ចំណូលពន្ធ | 1096 | 1096 | 1227 | 1220 | 1577 | 1911 | 484.7 | 558.6 | 565.8 | 661.8 | 699.9 | 585.1 |
| ពន្ធគយ | 376 | 376 | 424 | 395 | 513 | 573 | 135.5 | 151.7 | 157.2 | 200.0 | - | - |
| ពន្ធក្នុងស្រុក | - | - | - | - | - | - | - | - | - | - | 487.9 | 429.6 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | - | - | - | - | - | - | - | - | - | - | 212.1 | 155.5 |
| ចំណូលមិនមែនពន្ធ | 424 | 424 | 501 | 513 | 530 | 563 | 108.5 | 168.3 | 151.0 | 183.1 | 125.0 | 87.0 |
| អាជីវកម្មព្រៃឈើ | 28 | 29 | 15 | 7 | 2 | 3 | 0.5 | 0.7 | 0.3 | 0.9 | - | - |
| ប្រៃសណីយ៍ និងទូរគមនាគមន៍ | 124 | 122 | 123 | 120 | 94 | 123 | 11.4 | 30.0 | 11.7 | 30.0 | - | - |
| ចំណូលលើអចលនទ្រព្យ | - | - | - | - | - | - | - | - | - | - | 27.9 | 8.9 |
| លក់ទំនិញ និងសេវា | - | - | - | - | - | - | - | - | - | - | 88.8 | 70.7 |
| ចំណូលជាមូលធន | 8 | 9 | 16 | 31 | 19 | 152 | 2.7 | 4.6 | 15.4 | 354.7 | 0.0 | 0.0 |
| ចំណាយសរុប | 2332 | 2332 | 2948 | 2757 | 2932 | 3295 | 932.1 | 1020.1 | 1030.6 | 1191.9 | 923.9 | 680.2 |
| ចំណាយជាមូលធន | 976 | 977 | 1388 | 1171 | 1163 | 1328 | 390.5 | 394.7 | 423.8 | 429.1 | 367.1 | 216.5 |
| ចំណាយចរន្ត | 1356 | 1355 | 1560 | 1586 | 1769 | 1967 | 541.7 | 625.4 | 606.9 | 762.8 | 556.8 | 463.7 |
| អប់រំ និងសុខាភិបាល | 344 | 343 | 454 | 473 | 518 | 351 | 80.3 | 202.3 | 150.1 | 281.3 | - | - |
| ការពារ និងសន្តិសុខជាតិ | 404 | 405 | 438 | 411 | 423 | 451 | 78.1 | 116.7 | 155.3 | 170.1 | - | - |
| ក្រសួងផ្សេងៗទៀត | 636 | 637 | 668 | 702 | 828 | 1165 | 383.2 | 306.4 | 301.5 | 311.4 | - | - |
| បៀវត្សរ៍ | 517 | 509 | 587 | 615 | 640 | 711 | 140.5 | 210.3 | 230.6 | 240.6 | 199.7 | 164.3 |
| ឧបត្ថម្ភធន និង ជំនួយសង្គមកិច្ច | - | - | - | - | - | - | - | - | - | - | 61.9 | 119.3 |
| ឱនភាពជាទូទៅ | -804 | -802 | -1204 | -993 | -806 | -706 | -336.3 | -288.5 | -298.5 | 7.7 | -99.0 | -3.6 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 768 | 766 | 1249 | 886 | 864 | 1127 | 308.0 | 341.3 | 335.2 | 376.2 | 344.0 | 160.5 |
| ហិរញ្ញប្បទានក្នុងស្រុក | 36 | 37 | -45 | 106 | 148 | -396 | 28.3 | -52.8 | -36.7 | -383.9 | -245.0 | 156.9 |

Provisional for 2007. Q2 up to May. *Revised. Source: MEF web site.

## តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ឆ្នាំ១៩៩៩-២០០៧

| | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 Q1 | Q2 | Q3 | Q4 | 2007 Q1 | Q2 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | |
| ខេត្ត | 5.4 | -0.1 | 0.9 | 4.4 | 14.4 | 16.4 | 15.8 | 12.0 | 8.5 | 7.2 | 4.2 | 4.6 |
| ភ្នំពេញ - ទំនិញគ្រប់ប្រភេទ | -0.8 | 0.2 | 3.3 | 1.1 | 3.9 | 5.8 | 6.1 | 4.5 | 4.9 | 3.4 | 3.0 | 4.6 |
| - ម្ហូបអាហារ | -3.4 | -2.5 | 1.8 | 1.5 | 6.4 | 8.6 | 10.6 | 6.3 | 5.8 | 3.3 | 3.0 | 7.2 |
| - ដឹកជញ្ជូន | 6.6 | -4.2 | 0.3 | 4.9 | 9.7 | 11.4 | 9.7 | 10.0 | 10.1 | 6.8 | 5.2 | 5.0 |
| | | | | | | | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | |
| រៀលក្នុង ១ ដុល្លារ* | 3840.8 | 3916.3 | 3912.1 | 3973.3 | 4016.3 | 4119.7 | 4,094.8 | 4106.6 | 4145.3 | 4129.4 | 4063.0 | 4075.4 |
| រៀលក្នុង ១ បាតថៃ* | 95.8 | 88.2 | 91.1 | 95.8 | 99.9 | 102.6 | 103.5 | 108.0 | 110.3 | 113.0 | 113.7 | 118.0 |
| រៀលក្នុង ១០០ ដុងវៀតណាម* | 27.1 | 26.6 | 25.6 | 25.6 | 25.5 | 25.8 | 25.4 | 25.0 | 24.9 | 25.0 | 24.6 | 24.7 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 33.3 | 32.8 | 36.8 | 41.4 | 46.3 | 54.0 | 64.2 | 72.2 | 73.0 | 72.8 | 77.7 | 79.8 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 1105 | 1329 | 1521 | 1508 | 2088 | 2633 | 2,867 | 3110 | 3333 | 3250 | 3067 | 3100 |
| ថ្លៃសាំង (រៀល/លីត្រ) | 1760 | 2113 | 2084 | 2150 | 2833 | 3442 | 3,767 | 4000 | 4200 | 4050 | 3750 | 3900 |

Sources: CDRI, IMF, NIS, Ministry of Economy and Finance

## តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ១៩៩៩-២០០៧ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 Q1 | Q2 | Q3 | Q4 | 2007 Q1 | Q2 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | ពាន់លានរៀល | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 2589 | 3080 | 3737 | 4027 | 4797 | 5475 | 6,410 | 6682 | 6958 | 7224 | 8056 | 9048 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -759 | -876 | -849 | -698 | -467 | -450 | -699 | -637 | -497 | -282 | -263 | -172 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | 3 | -75 | -119 | -128 | -209 | -421 | -755 | -831 | -892 | -953 | -1176 | -1403 |
| ឥណទានដល់ផ្នែកឯកជន | 898 | 936 | 1059 | 1337 | 1817 | 2394 | 2,778 | 2997 | 3288 | 3628 | 4066 | 4537 |
| រូបិយវត្ថុទូទៅ M2 | 1830 | 2204 | 2888 | 3329 | 4330 | 5025 | 5,711 | 6045 | 6461 | 6942 | 7793 | 8876 |
| រូបិយវត្ថុ M1 | 540 | 609 | 813 | 937 | 1153 | 1323 | 1,449 | 1512 | 1563 | 1658 | 1794 | 1748 |
| រូបិយវត្ថុផ្សេងៗ | 1290 | 1595 | 2075 | 2392 | 3177 | 3702 | 4,262 | 4533 | 4898 | 5285 | 5999 | 7128 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| រូបិយវត្ថុទូទៅ M2 | 26.8 | 20.4 | 31.0 | 15.2 | 30.0 | 16.1 | 27.0 | 30.6 | 29.4 | 38.2 | 36.5 | 46.8 |
| រូបិយវត្ថុ M1 | 1.7 | 12.8 | 33.5 | 15.3 | 23.0 | 14.7 | 20.9 | 24.4 | 22.2 | 25.3 | 23.9 | 15.7 |
| រូបិយវត្ថុផ្សេងៗ | 41.4 | 23.6 | 30.0 | 15.2 | 32.8 | 16.6 | 33.6 | 32.8 | 31.9 | 42.7 | 40.7 | 57.3 |

Source: National Bank of Cambodia

## តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បំរែបំរួលធៀបនឹងឆ្នាំមុន (%) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2000 វិច្ឆិកា | 2003 | 2004 | 2005 | 2006 សីហា | វិច្ឆិកា | 2007 កុម្ភៈ | ឧសភា | សីហា | 2007 កុម្ភៈ | ឧសភា | សីហា |
| អ្នកធាក់ស៊ីក្លូ | 7594 | 8572 | 7614 | 7469 | 6063 | 7393 | 6534 | 9245 | 7126 | -17 | 8 | 18 |
| អ្នកលីសែង | 6233 | 6676 | 6895 | 6545 | 5238 | 7045 | 6010 | 9798 | 7704 | -8 | 33 | 47 |
| អ្នកលក់បន្លែតូចតាច | 5256 | 6532 | 6947 | 6000 | 5197 | 6125 | 6125 | 8951 | 9116 | -1 | 38 | 75 |
| អ្នករើសអេតចាយ | 2718 | 3944 | 4446 | 4416 | 4266 | 3903 | 4530 | 5533 | 6038 | -9 | 23 | 42 |
| អ្នកបំរើតាមភោជនីយដ្ឋាន* | 2111 | 4932 | 4448 | 4426 | 4292 | 4498 | 4078 | 5150 | 4193 | -13 | 21 | -2 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 4198 | 4177 | 4139 | 4365 | 4137 | 4653 | 4126 | 4531 | 4561 | 0 | 0 | 10 |
| កម្មកររោងចក្រកាត់ដេរ | 6701 | 9577 | 9277 | 8816 | 9264 | 8957 | 11146 | 8347 | 9033 | 21 | 6 | -2 |
| អ្នករត់ម៉ូតូឌុប | 8610 | 10092 | 9204 | 8201 | 6744 | 8386 | 9144 | 12,886 | 8979 | 3 | 47 | 33 |
| កម្មករសំណង់គ្មានជំនាញ | 5399 | 6558 | 6382 | 5918 | 6407 | 6028 | 5263 | 6075 | 5901 | -15 | -5 | -2 |
| កម្មករសំណង់មានជំនាញ | 13127 | 13111 | 12679 | 10316 | 9833 | 9466 | 10215 | 11,892 | 11,723 | -14 | 21 | 24 |

* Waitresses' earnings do not include meals and accommodation provided by shop owners.

Surveys on the revenue of waitresses, rice-field workers, unskilled workers, motorcycle taxi and construction workers began in February 2000. Source: CDRI